លក្ខខណ្ឌទូទៅនៃគណនីប្រាក់សន្សំ

១. សេចក្តីផ្តើម	
១.១.	**ធនាគារ អេ អឹម ខេ ម.ក** តទៅហៅថា“ **អេ អឹម ខេ** ”។ ចំណែកម្ចាស់គណនីប្រាក់សន្សំតទៅហៅថា **“អតិថិជន”**។ គ្រប់បុគ្គលដែលបានចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃ លើទម្រង់ស្នើសុំបើកគណនី ត្រូវបានចាត់ទុកជាម្ចាស់គណនីប្រាក់សន្សំ។
១.២.	លក្ខខណ្ឌទូទៅនៃគណនីប្រាក់សន្សំនេះ គឺជាកិច្ចព្រមព្រៀង រវាង **“អេ អឹម ខេ”** និង **“អតិថិជន”**។ នៅពេលដែលអតិថិជនចុះហត្ថលេខាលើទម្រង់ស្នើសុំបើកគណនីរបស់ អេ អឹម ខេ មានន័យថាអតិថិជនព្រមទទួលយក និងអនុវត្តតាមលក្ខខណ្ឌទូទៅទាំងនេះ។
១.៣.	រាល់លក្ខខណ្ឌដែលមានចែងនៅក្នុងលក្ខខណ្ឌនៃគណនីសន្សំនេះ មិនបង្ហាញអំពីលក្ខខណ្ឌរបស់ផលិតផល ឬ សេវាកម្មទាំងអស់ដែលផ្តល់ជូនដោយ អេ អឹម ខេ នោះទេ។ លក្ខខណ្ឌផ្សេងៗនឹងត្រូវបានបន្ថែម ដូចជាលក្ខខណ្ឌផ្សេងៗនៃផលិតផល និងសេវាកម្មជាក់លាក់ណាមួយ ឬ លក្ខខណ្ឌដែលតម្រូវដោយច្បាប់ ឬ លក្ខខណ្ឌផ្សេងៗដែលបានយល់ព្រមដោយអតិថិជនជាលាយលក្ខណ៍អក្សរ ឬ តាមរយៈមធ្យោបាយអេឡិចត្រូនិកផ្សេងៗ។ ប្រសិនបើលក្ខខណ្ឌទូទៅនៃគណនីសន្សំនេះ និងលក្ខខណ្ឌនៃផលិតផល ឬ សេវាកម្មជាក់លាក់ មានភាពមិនស្របគ្នា នោះលក្ខខណ្ឌនៃផលិតផល ឬ សេវាកម្មជាក់លាក់ត្រូវយកជាគោល។

២. និយមន័យផ្សេងៗ		
គណនី	៖	សំដៅលើគណនីប្រាក់សន្សំគ្រប់ប្រភេទរបស់ **អេ អឹម ខេ** មានដូចជា គណនីប្រាក់សន្សំមានកាលកំណត់ គណនីប្រាក់សន្សំមិនមានកាលកំណត់ គណនីមានកិច្ចសន្យា គណនីឯកត្តបុគ្គល គណនីរួមគ្នា គណនីស្ថាប័ន ឬ គណនីប្រាក់សន្សំផ្សេងៗទៀត ដែល **អេ អឹម ខេ** បង្កើតនាពេលអនាគត។
របាយការណ៍គណនី	៖	ជារបាយការណ៍គណនី ដែលមានបង្ហាញអំពីប្រវត្តិប្រតិបត្តិការហិរញ្ញវត្ថុរបស់អតិថិជនដែលបានធ្វើប្រតិបត្តិការជាមួយ អេ អឹម ខេ ដូចជា ការដកប្រាក់ ដាក់ប្រាក់ ផ្ទេរប្រាក់ ការកាត់កម្រៃសេវា ពន្ធផ្សេងៗ និងការបញ្ចូល ការប្រាក់ដោយ អេ អឹម ខេ ជាដើម។
គណនីសន្សំមានកាលកំណត់	៖	ជាគណនី ដែលតម្រូវឲ្យដាក់ប្រាក់តម្កល់តែម្តងនៅពេលបើកគណនី និង មានកាលកំណត់ដាក់លាក់ក្នុងការដកប្រាក់។ គណនីមានកាលកំណត់ មានដូចជា៖ គណនីមានកាលកំណត់ដកការប្រាក់ប្រចាំខែ និងគណនីមានកាលកំណត់ដកការប្រាក់ចុងវគ្គ ។ល។
គណនីសន្សំមិនមានកាលកំណត់	៖	ជាគណនី ដែល **អតិថិជន** អាចធ្វើប្រតិបត្តិការដកប្រាក់ ដាក់ប្រាក់បានដោយសេរី និងមិនកំណត់កាលបរិច្ឆេទដែលត្រូវដាក់ ឬដក។ ដោយឡែកចំពោះប្រភេទគណនីដែល ប្រើប្រាស់សម្រាប់ទូទាត់ផលិតផល និងសេវាកម្មផ្សេងទៀតរបស់ **អេ អឹម ខេ** អតិថិជនមិនអាចធ្វើការដកប្រាក់បាន**ទេ**។ គណនីមិនមានកាលកំណត់មានដូចជា៖ គណនីងាយស្រួល ឬ គណនីសំណាង ។ល។
គណនីសន្សំមានកិច្ចសន្យា	៖	ជាគណនី ដែលតម្រូវឲ្យ **អតិថិជន** ដាក់ប្រាក់ជាប្រចាំទៅតាមចំនួន និងកាលបរិច្ឆេទដែលបានព្រមព្រៀងជាមួយ **អេ អឹម ខេ** ហើយ **អតិថិជន** មិនអាចធ្វើការដកប្រាក់មុនកាលបរិច្ឆេទកំណត់បានទេ លុះត្រាស្នើសុំបិទគណនីតែម្តង។ គណនីមានកិច្ចសន្យា មានដូចជា៖ គណនីអនាគត គណនីសោធនិវត្តន៍ ឬ គណនីកូនឆ្លាត។ល។
គណនីឯកត្តបុគ្គល	៖	ជាគណនីដែលម្ចាស់គណនីជារូបវន្តបុគ្គលដែលបង្កើតគណនីនេះតែម្នាក់ឯង។
គណនីរួម	៖	ជាគណនីដែលមានម្ចាស់គណនីជារូបវន្តបុគ្គលចាប់ពី២នាក់ឡើងទៅ និងច្រើនបំផុតត្រឹម១០នាក់។
គណនីស្ថាប័ន	៖	ជាគណនីរបស់ស្ថាប័ន ជានីតិបុគ្គល ដែលមានដូចជា ក្រុមហ៊ុន អង្គការ សមាគម គម្រោង មូលនិធិ ។ល។
គណនីអសកម្ម	៖	គណនីអសកម្ម គឺជាគណនីប្រាក់សន្សំមិនមានកាលកំណត់ ទាំងឡាយណា ដែលមិនមានសកម្មភាពប្រតិបត្តិការ (មិនរាប់បញ្ចូលការបញ្ចូលការប្រាក់ ឬ ការកាត់ថ្លៃសេវាផ្សេងៗ ដោយប្រព័ន្ធឡើយ) លើស១២ខែ ឡើងទៅ។
ការដាក់ប្រាក់ដំបូង	៖	ទឹកប្រាក់ ដែលតម្រូវឲ្យ **អតិថិជន** ដាក់ចូលក្នុងគណនីនៅពេលបើកដំបូង។
សមតុល្យអប្បរមានៅក្នុងគណនី	៖	ទឹកប្រាក់អប្បរមា ដែល **អតិថិជន** ត្រូវរក្សាទុកក្នុងគណនី មិនអាចយកទៅធ្វើប្រតិបត្តិការបានទេ លុះត្រា **អតិថិជន** បិទគណនីតែម្តង។
សមតុល្យគណនីដែលអាចប្រើប្រាស់បាន	៖	ផលបូកនៃប្រាក់តម្កល់សម្រាប់ប្រតិបត្តិការគណនី និងសមតុល្យគណនីដែលអាចប្រើប្រាស់បាន។
សមតុល្យគណនីសរុប	៖	សំដៅទៅលើទឹកប្រាក់សរុបដែលមានទាំងអស់នៅក្នុងគណនី
ឯកសារបញ្ជាក់កម្មសិទ្ធិលើគណនី	៖	ប័ណ្ណសន្សំ វិញ្ញាបនបត្រ ឬ កាតអេធីអឹម ដែលចេញដោយ **អេ អឹម ខេ** ជូន **អតិថិជន**ជាម្ចាស់គណនីដើម្បីបង្ហាញនៅពេលស្នើសុំធ្វើប្រតិបត្តិការ
ម្ចាស់គណនី	៖	បុគ្គលម្នាក់ ឬ ច្រើននាក់ ដែលប្រើឈ្មោះរបស់ខ្លួន នៅពេលបើកគណនី ហើយបុគ្គលនោះ គឺទទួលខុសត្រូវចំពោះគណនីតាមរយៈហត្ថលេខា ឬ ផ្តិតស្នាមមេដៃ ប្រគល់សិទ្ធិ។ ប្រសិនបើគណនីមានម្ចាស់លើសពីម្នាក់ឡើងទៅ នោះពាក្យម្ចាស់គណនីសំដៅលើម្ចាស់គណនីទាំងអស់ និងបុគ្គលរៀងៗខ្លួន។ បើគណនីស្ថាប័ន នោះពាក្យម្ចាស់គណនីសំដៅលើស្ថាប័នទាំងមូល។
កាត អេ ធី អឹម	៖	កាតឥណពន្ធ ដែលអាចប្រើប្រាស់សំរាប់ធ្វើប្រតិបត្តិការលើគណនី ជាមួយការិយាល័យ អេ អឹម ខេ ភ្នាក់ងារ អេ អឹម ខេ និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ និងបណ្តាញប្រតិបត្តិការផ្សេងៗទៀតរបស់ អេ អឹម ខេ។
ភ្នាក់ងារ អេ អឹម ខេ	៖	បុគ្គលដែលបានចុះកិច្ចសន្យា និងទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ សម្រាប់ធ្វើប្រតិបត្តិការហិរញ្ញវត្ថុជូន អតិថិជន ជំនួសឲ្យអេ អឹម ខេ។ អតិថិជន អាចសម្គាល់បុគ្គលម្នាក់ថា ជាភ្នាក់ងាររបស់ អេ អឹម ខេ តាមរយៈការលើកយីហោនៅទីតាំងប្រតិបត្តិការ ឬ បិទផ្លាកសញ្ញាបញ្ជាក់ថាជាភ្នាក់ងាររបស់អេ អឹម ខេ ដោយមានពាណិជ្ជសញ្ញារបស់ អេ អឹម ខេ។
លក្ខខណ្ឌប្រតិបត្តិការគណនី	៖	ជាលក្ខខណ្ឌដែលម្ចាស់គណនីបានជ្រើសរើស ដើម្បីធ្វើប្រតិបត្តិការគណនី នៅលើទម្រង់ស្នើសុំបើកគណនី។
ក្រុមហ៊ុនធានារ៉ាប់រង	៖	ជាក្រុមហ៊ុនធានារ៉ាប់រង (អាយុជីវិត ឬ ទូទៅ) ដែលបានទទួលអាជ្ញាប័ណ្ណពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ហើយបានចុះកិច្ចព្រមព្រៀង ជាដៃគូសហការជាមួយ អេ អឹម ខេ ក្នុងការផ្តល់សេវាធានារ៉ាប់រង ដល់អតិថិជនរបស់ អេ អឹម ខេ។

៣. កម្មសិទ្ធិលើគណនីប្រាក់សន្សំ	
៣.១.	**<u>ចំពោះអតិថិជនឯកត្តជន៖</u>** **៣.១.១. គណនីឯកត្តបុគ្គល៖** ម្ចាស់គណនីឯកត្តបុគ្គល ជាអ្នកមានសិទ្ធិ និងកាតព្វកិច្ចពេញលេញលើគណនី។ **៣.១.២. គណនីរួម៖** ម្ចាស់គណនីទាំងអស់ ជាម្ចាស់នៃប្រាក់សន្សំមានកាតព្វកិច្ចដូចៗគ្នាលើគណនី។ លក្ខខណ្ឌដែលមានកំណត់ទាំងអស់ អនុវត្តចំពោះគ្រប់ម្ចាស់គណនីរួម។

	ម្ចាស់គណនីរួមនីមួយៗ មានទំនួលខុសត្រូវរួមគ្នា និងដោយឡែកៗពីគ្នា លើកាតព្វកិច្ចដែលមានជាមួយ **អេ អឹម ខេ**។ ចំណែកសិទ្ធិលើគណនីត្រូវយោងទៅតាម **លក្ខខណ្ឌប្រតិបត្តិការគណនី** ដែលម្ចាស់គណនីទាំងអស់បានព្រមព្រៀងជ្រើសរើស។ **<u>ចំពោះអតិថិជនដែលមានគណនីស្ថាប័ន៖</u>** **៣.១.៣. គណនីស្ថាប័ន៖** ស្ថាប័នគឺជាម្ចាស់គណនី មានសិទ្ធិ និងកាតព្វកិច្ចលើគណនី ហើយអាចអនុវត្តសិទ្ធិរបស់ខ្លួនបានតាមរយៈអ្នកតំណាងរបស់ស្ថាប័ន ដែលមានកំណត់នៅលើទម្រង់ស្នើសុំបើកគណនីស្ថាប័ន ឬ នៅលើសេចក្តីសម្រេចរបស់ស្ថាប័នក្នុងការចាត់តាំងអ្នកតំណាង។
៣.២.	ឯកសារបញ្ជាក់កម្មសិទ្ធិលើគណនី រួមមាន៖ ☞ **<u>កាត អេ ធី អឹម៖</u>** ត្រូវបានផ្តល់ជូនចំពោះ ម្ចាស់គណនីមានកិច្ចសន្យា ឬ ម្ចាស់គណនីឯកត្តបុគ្គល ឬ ម្ចាស់គណនីរួម ដែលបានជ្រើសរើសលក្ខខណ្ឌមានកាត អេ ធី អឹម សម្រាប់ធ្វើប្រតិបត្តិការ។ ☞ **<u>បំណុលសន្សំ៖</u>** ត្រូវបានផ្តល់ជូនចំពោះគណនីរួមគ្នាដែល **អតិថិជន**ជ្រើសរើសយកលក្ខខណ្ឌនៃការធ្វើប្រតិបត្តិការ ចាប់ពី២ (ពីរ) នាក់ឡើងទៅ។ គណនីប្រភេទស្ថាប័ន គណនីអនាគត និង គណនីសោធនិវត្តន៍។ ☞ **<u>វិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធិលើគណនីមានកាលកំណត់៖</u>** ត្រូវបានផ្តល់ជូន ចំពោះគណនីសន្សំមានកាលកំណត់។
៣.៣.	ការផ្ទៀងផ្ទាត់ភាពជាម្ចាស់លើគណនី តម្រូវឲ្យអតិថិជន បង្ហាញឯកសារបញ្ជាក់កម្មសិទ្ធិលើគណនី (៣.២) និង ប្រើប្រាស់លេខសម្ងាត់របស់កាត អេ ធី អឹម ឬ ផ្ទៀងផ្ទាត់ រូបថត គំរូហត្ថលេខា ឬ ស្នាមមេដៃ អាស្រ័យលើទំហំ ឬ ប្រភេទប្រតិបត្តិការ របស់អតិថិជន និងអាស្រ័យលើគោលនយោបាយរបស់ អេ អឹម ខេ។
៣.៤.	ក្នុងករណីសង្ស័យ ថាមានបុគ្គលណាម្នាក់ប្រើប្រាស់ឯកសារបញ្ជាក់កម្មសិទ្ធិលើគណនីរបស់អ្នកដទៃដោយពុំមានការអនុញ្ញាតពីម្ចាស់គណនី ឬ លិខិតប្រគល់សិទ្ធិមិនមានភាពច្បាស់លាស់ **អេ អឹម ខេ** មានសិទ្ធិមិនធ្វើប្រតិបត្តិការជូនបុគ្គលនោះទេ។
៣.៥.	នៅពេលដែល **អតិថិជន** មិនអាចបង្ហាញឯកសារបញ្ជាក់កម្មសិទ្ធិលើគណនី **អតិថិជន** ត្រូវអញ្ជើញមកការិយាល័យណាមួយរបស់ **អេ អឹម ខេ** ដោយភ្ជាប់ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណ ដើម្បីអាចធ្វើប្រើប្រតិបត្តិការគណនីបាន។
៤. ការបើកគណនីប្រាក់សន្សំ	
៤.១.	**អតិថិជន** បើកគណនីប្រាក់សន្សំ នៅការិយាល័យ ឬ ជាមួយបុគ្គលិករបស់ អេ អឹម ខេ អាស្រ័យទៅតាម ប្រភេទគណនីប្រាក់សន្សំ ដូចដែលមានកំណត់ដោយ អេ អឹម ខេ នៅលើខិត្តប័ណ្ណផ្សព្វផ្សាយ។
៤.២.	**អតិថិជន** ត្រូវបំពេញព័ត៌មានផ្ទាល់ខ្លួន ឬ ព័ត៌មានរបស់ស្ថាប័នដែលខ្លួនធ្វើជាអ្នកតំណាង ព្រមទាំងចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃស្តាំទទួលស្គាល់និងបញ្ជាក់ពីភាពត្រឹមត្រូវនៅលើ ទម្រង់ស្នើសុំបើកគណនី។
៤.៣.	រាល់ការផ្លាស់ប្តូរ ឬ កោសលុបណាមួយនៅលើទម្រង់ស្នើសុំបើកគណនីនេះ ត្រូវមានការទទួលស្គាល់ ដោយចុះហត្ថលេខាឲ្យបានត្រឹមត្រូវដោយ **អតិថិជន**។
៤.៤.	**អតិថិជន** ត្រូវដាក់ជូន **អេ អឹម ខេ** នូវឯកសារបញ្ជាក់អត្តសញ្ញាណ និងឯកសារផ្លូវការផ្សេងៗទៀត ទៅតាមការស្នើសុំពី **អេ អឹម ខេ** អនុលោមតាមគោលនយោបាយស្គាល់អតិថិជន របស់ អេ អឹម ខេ។
៤.៥.	**អតិថិជន** ត្រូវដាក់ប្រាក់តម្កល់ក្នុងគណនីនោះនូវចំនួនទឹកប្រាក់ស្មើ ឬ ច្រើនជាងចំនួនអប្បបរមាទៅតាមប្រភេទគណនីនីមួយៗ ដែលបានកំណត់នៅក្នុងលក្ខខណ្ឌជាក់លាក់របស់គណនីប្រភេទនោះនៅលើខិត្តប័ណ្ណផ្សព្វផ្សាយរបស់ **អេ អឹម ខេ**។
៤.៦.	ចំពោះគណនីដែលបានបើកដោយបុគ្គលិកផ្នែកលក់របស់ អេ អឹម ខេ **អតិថិជន** ជាម្ចាស់គណនី អាចនឹងតម្រូវឲ្យអញ្ជើញមកការិយាល័យ **អេ អឹម ខេ** ណាមួយ ដើម្បីផ្តល់ ព័ត៌មានបន្ថែម។
៤.៧.	ក្រោយពីបើកគណនីរួច **អតិថិជន** នឹងទទួលបានឯកសារបញ្ជាក់កម្មសិទ្ធិលើគណនីដូចមានរៀបរាប់ក្រង់ចំណុច ៣.២. ខាងលើ។
៤.៨.	**សម្រាប់គណនីឯកត្តជន និងគណនីរួមប៉ុណ្ណោះ** អតិថិជន យល់ព្រម និងធានាអះអាងថា គណនីដែលបានស្នើសុំបើកនេះ ជាគណនីរបស់អតិថិជនផ្ទាល់ និងសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់អតិថិជនតែប៉ុណ្ណោះ។ អតិថិជន មិនត្រូវបើកគណនីនេះ ឬធ្វើប្រតិបត្តិការគណនីនេះ ឬថែរក្សាគណនីនេះ ជំនួសឱ្យបុគ្គលផ្សេងណាមួយឡើយ មិនថាជាអ្នកតំណាង ជាភ្នាក់ងារ ឬជាបេធនបាល។ រាល់គណនីណាដែលត្រូវបានរកឃើញថា បានបើកសម្រាប់អត្ថប្រយោជន៍នៃបុគ្គលផ្សេង ឬបើកក្រោមការបង្គាប់បញ្ជារបស់បុគ្គលផ្សេង ដោយគ្មានការអនុម័តជាលាយលក្ខណ៍អក្សរជាមុនពី អេ អឹម ខេ នឹងត្រូវប្រឈមនឹងការរឹតត្បិតប្រតិបត្តិការ ឬផ្អាកដំណើរការ ឬបង្កក ឬបិទ ឬត្រូវបានចាត់វិធានការសមស្របផ្សេងៗ ដោយ អេ អឹម ខេ។
៥. ការដាក់ប្រាក់	
៥.១.	**អតិថិជន** ដាក់ប្រាក់ចូលគណនីប្រាក់សន្សំ នៅការិយាល័យ ឬ ម៉ាស៊ីនដាក់ប្រាក់ស្វ័យប្រវត្តិ ឬ ភ្នាក់ងារ ឬ អន្តរការិយ ឬ ជាមួយបុគ្គលិករបស់ អេ អឹម ខេ អាស្រ័យទៅតាម ប្រភេទគណនីប្រាក់សន្សំ និងទំហំប្រតិបត្តិការ ដូចដែលមានកំណត់ដោយ អេ អឹម ខេ។
៥.២.	**<u>ការដាក់ប្រាក់សន្សំនៅការិយាល័យ អេ អឹម ខេ៖</u>** ✓ រាល់ការដាក់ប្រាក់ អ្នកស្នើសុំ ឬ**អតិថិជន** ត្រូវបំពេញប័ណ្ណដាក់ប្រាក់ ដែលបានកំណត់ដោយ អេ អឹម ខេ។ អ្នកស្នើសុំ ឬ**អតិថិជន** ត្រូវធានាថារាល់ព័ត៌មានដែលបានបំពេញនៅក្នុងប័ណ្ណដាក់ប្រាក់ពិតជាត្រឹមត្រូវ។ ✓ រាល់ការដាក់ប្រាក់ដោយប្រើលេខសម្ងាត់(ឆូតកាតនិងវាយលេខសម្ងាត់**អតិថិជន** មិនតម្រូវឲ្យបំពេញប័ណ្ណដាក់ប្រាក់ទេហើយអតិថិជននឹងទទួលបានវិក្កយបត្របញ្ជាក់ពីការធ្វើប្រតិបត្តិការដូចនៅភ្នាក់ងារ។ ✓ រាល់ការផ្លាស់ប្តូរ ឬ កោសលុបណាមួយនៅលើទម្រង់បែបបទនេះ ត្រូវមានការទទួលស្គាល់ និងចុះហត្ថលេខាឬ ផ្តិតស្នាមមេដៃបញ្ជាក់ឲ្យបានត្រឹមត្រូវដោយ អ្នកស្នើសុំ ឬ **អតិថិជន**។ ✓ រាល់ការដាក់ប្រាក់សន្សំណាមួយជាមូលប្បទានប័ត្រ ឬ ប័ណ្ណផ្ទេរប្រាក់ របស់ធនាគារ ត្រូវចាត់ទុកមានសុពលភាពតែនៅពេលដែលឧបករណ៍ទូទាត់នោះ ត្រូវបានដាក់ទាត់រួចនិងទូទាត់ត្រឹមត្រូវ។ ក្នុងករណីដែលឧបករណ៍ទូទាត់នោះត្រូវបានបង្វិលទៅឲ្យ **អតិថិជន** វិញ ដោយមិនអាចធ្វើការទូទាត់ដោយប្រការណាមួយ ដូច្នេះ **អតិថិជន** ត្រូវមានកាតព្វកិច្ចបង់លើថ្លៃសេវាណាមួយដែលអាចកើតមានឡើង (ប្រសិនបើមាន)។
៥.៣.	រាល់ការដាក់ប្រាក់ជាមួយភ្នាក់ងារ ឬ បុគ្គលិករបស់ **អេ អឹម ខេ** ឬ ម៉ាស៊ីនដាក់ប្រាក់ស្វ័យប្រវត្តិ (CDM) អ្នកស្នើសុំ ឬ **អតិថិជន**ត្រូវមានកាត អេ ធី អឹម របស់ខ្លួន។ ដើម្បីសម្រេចប្រតិបត្តិការដាក់ប្រាក់ **អតិថិជន** ត្រូវបញ្ចូលលេខសម្ងាត់របស់កាត អេ ធី អឹម ដោយខ្លួនឯង និងមិនត្រូវប្រាប់លេខសម្ងាត់នេះទៅភ្នាក់ងារ ឬ បុគ្គលិក **អេ អឹម ខេ** ឬ នរណាម្នាក់ឲ្យដឹងឡើយ។

៥.៤.	**អតិថិជន**អាចដាក់ប្រាក់បានទៅតាមទំហំ ដែលបានកំណត់នៅតាមបណ្តាញនីមួយៗរបស់ **អេ អឹម ខេ**។
៥.៥.	ក្រោយធ្វើប្រតិបត្តិការដាក់ប្រាក់ **អតិថិជន** នឹងទទួលបានប័ណ្ណដាក់ប្រាក់ ឬ វិក្កយបត្រមួយសន្លឹក ឬ សារទៅកាន់ទូរស័ព្ទដៃរបស់**អតិថិជន**។ **អតិថិជន** ត្រូវរក្សាទុកប័ណ្ណដាក់ប្រាក់ ឬវិក្កយបត្រ ឬ សារទូរស័ព្ទ នោះដោយខ្លួនឯង សម្រាប់ធ្វើការផ្ទៀងផ្ទាត់ ។
៥.៦.	រាល់ក្រដាសប្រាក់ដែលទទួលបានពីអតិថិជន ឬទទួលបានពីការដាក់ប្រាក់តាមរយៈម៉ាស៊ីនដាក់ប្រាក់ស្វ័យប្រវត្តិ (CDM) ដែលមានសភាពចាស់ ខូច ប្រឡាក់ ទទឹក ឬរំហែក ដែលមានលក្ខណៈមិនអាចទទួលយកបាន ឬចាចរនៅលើទីផ្សារមិនបាន នោះ អេ អឹម ខេ មានសិទ្ធិបដិសេធក្នុងការទទួលយកក្រដាសប្រាក់នោះ ហើយអាចទំនាក់ទំនង និងអញ្ជើញអតិថិជនឲ្យមកប្តូរ ឬទទួលយកក្រដាសប្រាក់ទាំងនោះវិញ។ ក្នុងករណីអតិថិជនមិនព្រមមកប្តូរក្រដាសប្រាក់ទាំងនោះវិញទេ អតិថិជនអនុញ្ញាតឲ្យ អេ អឹម ខេ មានសិទ្ធិក្នុងការកាត់សាច់ប្រាក់ចេញពីគណនីរបស់អតិថិជន តាមចំនួនទឹកប្រាក់នៃក្រដាសប្រាក់មិនអាចប្តូរបាននោះដោយគ្មានលក្ខខណ្ឌ។
៦. ការដកប្រាក់	
៦.១.	**អតិថិជន** ដកប្រាក់ពីគណនីប្រាក់សន្សំ នៅការិយាល័យ ឬ ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ ឬ ភ្នាក់ងារ ឬ ជាមួយបុគ្គលិករបស់ អេ អឹម ខេ អាស្រ័យទៅតាម ប្រភេទគណនីប្រាក់សន្សំ និងទំហំប្រតិបត្តិការ ដូចដែលមានកំណត់ដោយ អេ អឹម ខេ ។
៦.២.	**ដែនកំណត់នៃការដកប្រាក់៖ អតិថិជន** អាចដកប្រាក់ទៅតាមចំនួនដែលបានកំណត់ដោយគោលនយោបាយរបស់ អេ អឹម ខេ។
៦.៣.	**<u>លក្ខខណ្ឌនៃការដកប្រាក់នៅការិយាល័យ អេ អឹម ខេ៖</u>** ✓ រាល់ការដកប្រាក់ ម្ចាស់គណនីត្រូវបំពេញប័ណ្ណដកប្រាក់ដោយមានការចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃឲ្យបានត្រឹមត្រូវដោយអនុលោមទៅតាមលក្ខខណ្ឌនៃប្រតិបត្តិការគណនី ដែលម្ចាស់គណនីបានព្រមព្រៀងនៅក្នុងឯកសារពេលបើកគណនីដំបូង និងត្រូវផ្តល់ ឬ បង្ហាញនូវឯកសារដែលបញ្ជាក់កម្មសិទ្ធិលើគណនី ឬ ឯកសារដទៃផ្សេងទៀតមក **អេ អឹម ខេ** តាមការស្នើសុំសម្រាប់ធ្វើការផ្ទៀងផ្ទាត់។ ✓ រាល់ការដកប្រាក់ដោយប្រើលេខសម្ងាត់(ឆូតកាតនិងវាយលេខសម្ងាត់)**អតិថិជន** មិនតម្រូវឲ្យបំពេញប័ណ្ណដកប្រាក់ទេហើយអតិថិជននឹងទទួលបានវិក្កយបត្របញ្ជាក់ពីការធ្វើប្រតិបត្តិការដូចនៅភ្នាក់ងារ។ចំនួនទឹកប្រាក់ដែលអាចដកដោយប្រើលេខសម្ងាត់ត្រូវយោងតាមគោលនយោបាយដែលបានកំណត់ដោយអេ អឹម ខេ។ ✓ រាល់ការផ្លាស់ប្តូរ ឬ កោសលុបណាមួយនៅលើប័ណ្ណដកប្រាក់ ត្រូវមានការទទួលស្គាល់និងចុះហត្ថលេខាឬ ផ្តិតស្នាមមេដៃបញ្ជាក់ឲ្យបានត្រឹមត្រូវដោយ **អតិថិជន**។ ✓ **គណនីមិនមានកាលកំណត់៖** ការដកប្រាក់សន្សំអាចធ្វើទៅបានដោយ**អតិថិជន**ជាម្ចាស់គណនីផ្ទាល់ ឬ អ្នកដែលត្រូវបានផ្តល់សិទ្ធិជាផ្លូវការដោយម្ចាស់គណនីជាលាយលក្ខណ៍អក្សរក្នុងការដកប្រាក់។ ដោយឡែក **ប័ណ្ណប្រគល់សិទ្ធិ** មិនអនុញ្ញាតឲ្យមានការកោសលុបទេ។ ✓ **គណនីមានកាលកំណត់ និងគណនីមានកិច្ចសន្យា៖ អតិថិជន** ពុំអាចដកប្រាក់មុនកាលកំណត់បានទេលុះត្រា**អតិថិជន**បិទគណនីតែម្តង។
៦.៤.	**<u>លក្ខខណ្ឌនៃការដកប្រាក់នៅភ្នាក់ងារ អេ អឹម ខេ បុគ្គលិក អេ អឹម ខេ និងម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM និង CDM)៖</u>** ✓ ម្ចាស់គណនីត្រូវមាន កាត អេ ធី អឹម របស់ខ្លួន និងបញ្ចូលលេខសម្ងាត់របស់កាត អេ ធី អឹម ដោយខ្លួនឯង ដើម្បីធ្វើប្រតិបត្តិការ។ ✓ **អតិថិជន** មិនត្រូវប្រាប់លេខសម្ងាត់ទៅភ្នាក់ងារ ឬ បុគ្គលិក **អេ អឹម ខេ** ឬ ជនណាម្នាក់ ដើម្បីធ្វើប្រតិបត្តិការជំនួសខ្លួនឡើយ។ រាល់ការបាត់បង់ដែលកើតចេញពីការមិនរក្សាទុកលេខសម្ងាត់ឲ្យបានត្រឹមត្រូវ ជាការទទួលខុសត្រូវរបស់ម្ចាស់គណនី។
៧. ការបង្កក/ការបិទគណនី	
៧.១.	**ការបង្កកគណនី** **អេ អឹម ខេ នឹងធ្វើការព្យួរ/បង្កកគណនីរបស់អតិថិជនដូចតទៅ៖**
៧.១.១.	**មានការស្នើសុំពីម្ចាស់គណនី ៖** ការស្នើសុំបង្កកគណនី គឺតម្រូវឲ្យម្ចាស់គណនីមកកាន់ការិយាល័យ អេ អឹម ខេ ដើម្បីបំពេញពាក្យស្នើសុំបង្កកគណនី និងត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ រួមទាំងឯកសារផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធទៅនឹងគណនី ព្រមទាំងចុះហត្ថលេខា ឬ ស្នាមមេដៃនៅលើពាក្យស្នើសុំបង្កកគណនី ដើម្បីបញ្ជាក់អំពីការយល់ព្រម ។ ក្នុងករណីនេះ **អេ អឹម ខេ** នឹងធ្វើការដោះបង្កកគណនីរបស់អតិថិជន លុះត្រាតែមានការស្នើសុំត្រឹមត្រូវពីម្ចាស់គណនីនោះ ។
៧.១.២.	**មានការស្នើសុំ ឬ បង្គាប់បញ្ជាពីអាជ្ញាធរសាធារណៈ ៖** ក្នុងករណី ដែលមានការស្នើសុំ ឬ បង្គាប់ពីអាជ្ញាធរសាធារណៈ (តុលាការ ធនាគារជាតិនៃកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ល។) ឲ្យបង្កកគណនីរបស់អតិថិជនណាមួយ **អេ អឹម ខេ** នឹងធ្វើការបង្កកគណនីរបស់អតិថិជននោះ ដោយពុំមានការជូនដំណឹងដល់អតិថិជនឡើយ ។ ក្នុងករណីនេះ **អេ អឹម ខេ** នឹងធ្វើការដោះបង្កកគណនីរបស់អតិថិជនវិញ លុះត្រាតែមានការស្នើសុំ ឬ បង្គាប់ពីអាជ្ញាធរសាធារណៈ ដែលបានស្នើសុំ ឬ បង្គាប់ឲ្យបង្កកគណនីរបស់អតិថិជននោះ ។
៧.១.៣.	**មានការស្នើសុំពីបុគ្គលមានសិទ្ធិអំណាចលើស្ថាប័ន ៖ អេ អឹម ខេ** តាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចធ្វើការបង្កកគណនីស្ថាប័ន នៅក្នុងករណីដែលមានការស្នើសុំពីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ណាម្នាក់របស់ស្ថាប័ន មានដូចជា ម្ចាស់ភាគហ៊ុន ឬ អភិបាល ឬ បុគ្គលដែលទទួលបានសិទ្ធិពីក្រុមហ៊ុនតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ។ល។ ក្នុងករណីនេះ **អេ អឹម ខេ** នឹងបញ្ឈប់ការបង្កកគណនីរបស់អតិថិជន នៅពេលដែលទទួលបានការស្នើសុំពីបុគ្គលដែលមានសិទ្ធិដូចដែលបានបញ្ជាក់ក្នុងចំណុចនេះ។
៧.១.៤.	**មានការសង្ស័យថាគណនីនោះ មានការជាប់ទាក់ទងទៅនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬ បទល្មើសព្រហ្មទណ្ឌ ៖** នៅពេលដែល **អេ អឹម ខេ** បានរកឃើញថាគណនី របស់អតិថិជនមានការជាប់ទាក់ទងនឹងប្រតិបត្តិការសង្ស័យនៃការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬ បទល្មើសព្រហ្មទណ្ឌ នោះ **អេ អឹម ខេ** តាមឆន្ទានុសិទ្ធិរបស់ខ្លួន នឹងធ្វើការបង្កកគណនី ជាបណ្តោះអាសន្ន ដើម្បីធ្វើការស៊ើបអង្កេត ដោយមិនមានការជូនដំណឹងទៅកាន់អតិថិជនឡើយ ។ **អេ អឹម ខេ** នឹងធ្វើការដោះបង្កកគណនីរបស់អតិថិជនវិញ លុះត្រាតែមានភស្តុតាងបញ្ជាក់ច្បាស់ថា គណនីនោះពុំមានការជាប់ទាក់ទងទៅនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬ បទល្មើសព្រហ្មទណ្ឌណាមួយឡើយ ។
៧.២.	**ការបិទគណនី**
៧.២.១.	ការបិទគណនី ត្រូវធ្វើឡើងដោយមានការស្នើសុំពី ម្ចាស់គណនីផ្ទាល់ ឬ បុគ្គលដែលមានសិទ្ធិ ឬសេចក្តីសម្រេចចេញពីអភិបាល ឬម្ចាស់ភាគទុនិករបស់ស្ថាប័ន ស្របតាមលក្ខន្តិក:របស់ស្ថាប័ននោះ ដោយត្រូវបំពេញពាក្យសុំបិទគណនីនៅតាមការិយាល័យ **អេ អឹម ខេ** ណាមួយ និងត្រូវប្រគល់ឯកសារបញ្ជាក់កម្មសិទ្ធិលើគណនីមក **អេ អឹម ខេ**។ ក្រោយពេលបិទគណនី **អតិថិជន** នឹងទទួលបានសមតុល្យសរុបដែលមានក្នុងគណនីបូកបន្ថែមការប្រាក់ និងក្រោយការកាត់រាល់កម្រៃសេវា ប្រាក់ដែល **អតិថិជន** ជំពាក់ **អេ អឹម ខេ** និងប្រាក់ដែលត្រូវទូទាត់ដូចមានកំណត់ក្នុងចំណុច**១៨**។
៧.២.២.	**អតិថិជន** យល់ព្រមឲ្យ **អេ អឹម ខេ** ធ្វើការបង្កក ឬ បិទគណនីរបស់ខ្លួន ដោយពុំចាំបាច់ជូនដំណឹងទៅកាន់ **អតិថិជន** ចំពោះគណនីណាមួយ ដែល (ករណីខាងក្រោមនេះគ្រាន់

	តែជាឧទាហរណ៍ខ្លះៗតែប៉ុណ្ណោះ)៖ ៧.២.២.១ គ្មានសមតុល្យសរុបក្នុងគណនី ក្នុងរយៈពេលកំណត់ណាមួយ ដែលបានកំណត់ក្នុងគោលនយោបាយ ឬនីតិវិធីរបស់ **អេ អឹម ខេ**។ ៧.២.២.២ មិនបានផ្តល់ព័ត៌មានតាមការស្នើសុំ ឬ គណនីដែលមិនមានព័ត៌មានពេញលេញ។ ៧.២.២.៣. មានការស្នើសុំ ឬ បង្គាប់បញ្ជាពីអាជ្ញាធរសាធារណៈ ការតម្រូវដោយច្បាប់ក្នុងប្រទេស ឬ កិច្ចព្រមព្រៀងអន្តរជាតិដែលរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានចូលរួមអនុវត្ត និងជាសមាជិក ។ ៧.២.២.៤. មានឈ្មោះនៅក្នុងបញ្ជីទណ្ឌកម្ម (Sanctions List) របស់អង្គការសហប្រជាជាតិ (UN Sanctions List) បញ្ជីទណ្ឌកម្មរបស់សហភាពអ៊ឺរ៉ុប (EU Sanctions List) បញ្ជីទណ្ឌកម្មរបស់ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិបរទេស (OFAC Sanctions List) បញ្ជីទណ្ឌកម្មរបស់ក្រុមការងារចំណាត់ការហិរញ្ញវត្ថុ (FATF Sanctions List) និងបញ្ជីទណ្ឌកម្មផ្សេងៗទៀតដែលចេញដោយនិយ័តករ។ ៧.២.២.៥ មានហានិភ័យខ្ពស់ជាប់ទាក់ទងទៅនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬ បទល្មើសព្រហ្មទណ្ឌ។ ៧.២.២.៦ **អេ អឹម ខេ** មានមូលហេតុសមស្របបញ្ជាក់ថា គណនី ឬ ទឹកប្រាក់នៅក្នុងគណនីមានប្រភពមិនស្របច្បាប់ ឬ ត្រូវបានសង្ស័យថាជាទឹកប្រាក់ដែលទទួលបានដោយមិនស្របច្បាប់ ឬទឹកប្រាក់នោះជាទឹកប្រាក់ដែលទទួលបានមកពីការបោកបន្លំដោយឥតហេតុពីភាគីដទៃ។ និង ៧.២.២.៧ តាមឆន្ទានុសិទ្ធិរបស់ **អេ អឹម ខេ**។ **អេ អឹម ខេ** ពុំមានទំនួលខុសត្រូវចំពោះការបាត់បង់ណាមួយរបស់អតិថិជន ដែលបណ្តាលមកពីការបង្កក ឬ បិទគណនីនេះឡើយ។
៧.២.៣.	ក្នុងករណីគណនីដែលបានបើកថ្មី និងមានសមតុល្យសូន្យដោយរាប់ចាប់ពីថ្ងៃបើកដំបូងរហូតដល់រយៈពេលធំជាង៩០ថ្ងៃ នោះអតិថិជនយល់ព្រមអនុញ្ញាតឱ្យ អេ អឹម ខេ ធ្វើការបិទគណនីដោយស្វ័យប្រវត្តិ ដោយពុំចាំបាច់ធ្វើការជូនដំណឹងជាមុនឡើយ។
៧.២.៤	មុនពេលបិទគណនី **អេ អឹម ខេ** នឹងធ្វើការទូទាត់រាល់កម្រៃសេវា បំណុលដែល **អតិថិជន** នៅជំពាក់ **អេ អឹម ខេ** ហើយចំពោះសមតុល្យសរុបដែលនៅសល់ក្នុងគណនី នឹងត្រូវចាត់ចែងទៅតាមការតម្រូវរបស់អាជ្ញាធរសាធារណៈ និង/តាមនីតិវិធីកំណត់ដោយ **អេ អឹម ខេ** ។
៧.៣	ប្រសិនបើ **អេ អឹម ខេ** ពិនិត្យឃើញថាគណនីអតិថិជនមិនបានដំណើរការស្របតាមគោលការណ៍របស់ **អេ អឹម ខេ** នោះ**អេ អឹម ខេ** នឹងធ្វើការបង្កក ឬ បិទគណនីរបស់អតិថិជន។ **អេ អឹម ខេ** មិនទទួលខុសត្រូវលើការបាត់បង់ណាមួយដែលបណ្តាលពីការបង្កក ឬ បិទគណនីនេះឡើយ។
៧.៤	អតិថិជនយល់ព្រមថា **អេ អឹម ខេ** រក្សាសិទ្ធិក្នុងការបិទ និងកាត់យកត្រឡប់មកវិញនូវការខាតបង់ផ្នែកហិរញ្ញវត្ថុទាំងអស់ដែលកើតចេញពីសកម្មភាពរបស់អតិថិជនដែល អេ អឹម ខេ បានសម្គាល់ ឬ រកឃើញថា អតិថិជនបានប្រព្រឹត្តសកម្មភាពកេងប្រវ័ញ្ចលើ អេ អឹម ខេ រួមបញ្ចូលទាំង ការសាកល្បងលើការប្រែប្រួលនៃអត្រាប្តូរប្រាក់បរទេស ការលេងសើចការទទួលបានពិន្ទុជាដើម។ ដើម្បីជៀសវាងការភ័ន្តច្រលំ ករណីដែលអតិថិជនធ្វើប្រតិបត្តិការឆ្លងរបិយវត្ថុនូវចំនួនទឹកប្រាក់តិចតួចជាច្រើនលើកច្រើនសារក្នុងមួយថ្ងៃដើម្បីទទួលបានផលចំណេញពីការប្តូរប្រាក់ ក៏ត្រូវចាត់ទុកថាជាសកម្មភាពកេងប្រវ័ញ្ចលើ អេ អឹម ខេ ផងដែរ។
៨. គណនីដែលប្រើប្រាស់សម្រាប់ទូទាត់	
៨.១.	សម្រាប់គណនីមានកាលកំណត់ គណនីសោធននិវត្តន៍ និងគណនីអនាគត តម្រូវឲ្យអតិថិជន មានគណនីបន្ថែមមួយទៀតសម្រាប់ធ្វើការទូទាត់ប្រាក់សន្សំ(Pay In / Pay Out) ចូលទៅក្នុងគណនីមានកាលកំណត់ គណនីសោធនិវត្តន៍ និងគណនីអនាគតទៅតាមកាលបរិច្ឆេទដែលបានកំណត់។
៨.២.	អតិថិជន មិនអាចបិទគណនីប្រើប្រាស់សម្រាប់ទូទាត់នេះទេ លុះត្រាតែ អតិថិជន ស្នើសុំបិទគណនីមានកាលកំណត់ គណនីសោធនិវត្តន៍ និងគណនីអនាគត ឬគណនីដល់កាលកំណត់។
៩. គណនីអសកម្ម (Dormant Account)	
៩.១.	គណនីអសកម្ម សំដៅលើគណនីរបស់អតិថិជនដែលគ្មានសកម្មភាពប្រតិបត្តិការ (លើកលែងប្រតិបត្តិការធ្វើឡើងដោយ អេ អឹម ខេ ដូចជា ការទូទាត់ការប្រាក់ និងការកាត់កម្រៃសេវាជាដើម) លើសពី ១២ខែ ជាប់ៗគ្នា។ ក្នុងករណីគណនីមិនមានសកម្មភាពប្រតិបត្តិការក្នុង រយៈពេល៣ឆ្នាំ ឬ ១០៩៥ថ្ងៃជាប់គ្នា អតិថិជន យល់ព្រមឲ្យ អេ អឹម ខេ កាត់យកកម្រៃសេវាពីគណនីនោះ ដោយយោងតាមគោលនយោបាយរបស់ **អេ អឹម ខេ** និងមិនចាំបាច់ជូនដំណឹងជាមុនទៅកាន់អតិថិជនឡើយ។
៩.២.	រាល់គណនីអសកម្មដែលនៅតែបន្តអសកម្មរយៈពេល១០ឆ្នាំ ជាប់គ្នា **អេ អឹម ខេ** នឹងធ្វើការបិទគណនីទាំងនោះ រួចផ្ទេរសមតុល្យតណាទានរបស់គណនីទាំងនោះ ទៅធនាគារជាតិនៃកម្ពុជា។
១០. ការកែប្រែព័ត៌មានម្ចាស់គណនី	
១០.១.	**អតិថិជន** មានកាតព្វកិច្ច ធ្វើបច្ចុប្បន្នកម្មព័ត៌មានផ្ទាល់ខ្លួន ឬ ស្ថាប័ន ដើម្បីធានាថាព័ត៌មានដែលផ្តល់ជូន **អេ អឹម ខេ** មានភាពត្រឹមត្រូវ។ ការស្នើសុំកែប្រែព័ត៌មានគណនី **អតិថិជន** ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរ និងត្រូវអញ្ជើញមកការិយាល័យ អេ អឹម ខេ។
១០.២.	ការកែប្រែព័ត៌មានម្ចាស់គណនី មានដូចជា៖ ការផ្លាស់ប្តូរ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត មុខរបរ ឯកសារបញ្ជាក់អត្តសញ្ញាណ លេខទូរស័ព្ទ សារអេឡិចត្រូនិក អាសយដ្ឋាន ឬ ការកែប្រែក្នុខណ្ឌប្រតិបត្តិការគណនី ឬ ការកែប្រែក្នុនិក:ស្ថាប័ន ឬ ការផ្លាស់ប្តូរគំរូហត្ថលេខា ឬ ស្នាមមេដៃ ឬ ធ្វើបច្ចុប្បន្នកម្មលិខិតអនុញ្ញាតអាជីវកម្ម ឬ ការផ្លាស់ប្តូរម្ចាស់ភាគទុនិក។ល។
១០.៣.	ផលវិបាកទាំងឡាយណាដែលកើតចេញពីការ មិនបានមកផ្លាស់ប្តូរ ឬ ធ្វើបច្ចុប្បន្នកម្មព័ត៌មានរបស់ម្ចាស់គណនី ជាការទទួលខុសត្រូវផ្ទាល់របស់ម្ចាស់គណនី។
១០.៤.	**អតិថិជន** មិនអាចស្នើសុំកែប្រែព័ត៌មានម្ចាស់គណនី ដែលនាំឲ្យមានការផ្ទេរកម្មសិទ្ធិលើគណនីប្រាក់សន្សំទេ។
១១. លក្ខខណ្ឌទូទៅនៃកាត អេ ធី អឹម និងលេខសម្ងាត់	
១១.១.	**អតិថិជន** អាចស្នើសុំភ្ជាប់គណនីច្រើនជាងមួយ ជាមួយនឹងកាត អេ ធី អឹម របស់ខ្លួន សម្រាប់គណនីដែលមានលេខសម្គាល់អតិថិជនតែមួយ។
១១.២.	នៅពេលទទួលបានកាត អេ ធី អឹម **អតិថិជន** ត្រូវធ្វើការផ្លាស់ប្តូរលេខសម្ងាត់របស់កាត អេ ធី អឹម ភ្លាមៗ ដោយមិនត្រូវយកលេខសម្ងាត់ដើមប្រើប្រាស់តែម្តងទេ ដើម្បីទុកប្រើប្រាស់ធ្វើប្រតិបត្តិការ និងរក្សាការសម្ងាត់។
១១.៣.	នៅពេល **អតិថិជន** ធ្វើប្រតិបត្តិការ **អតិថិជន** ត្រូវបញ្ចូលលេខសម្ងាត់របស់កាត ដោយខ្លួនឯងជានិច្ច។
១១.៤.	លេខសម្ងាត់របស់កាត ត្រូវមានលេខ ៦ ខ្ទង់ ដែលត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖ ✓ មិនត្រូវដាក់លេខសម្ងាត់ ជាលេខរៀងបន្តបន្ទាប់គ្នា ឧទាៈ 123456 ឬ 987654 ជាដើម ✓ មិនត្រូវដាក់លេខសម្ងាត់ ដូចគ្នាបេះបិទ ឧទាៈ 000000 ឬ 999999 ✓ មិនត្រូវដាក់លេខសម្ងាត់ ដូចលេខទូរស័ព្ទរបស់ខ្លួន

	✓ មិនត្រូវដាក់លេខសម្ងាត់ ដូចថ្ងៃខែឆ្នាំកំណើត របស់ខ្លួន ✓ មិនត្រូវដាក់លេខសម្ងាត់ ដែលអ្នកដ៏ទៃដឹង ឬ ងាយដឹង។
១១.៥.	ប្រសិនបើ **អតិថិជន** បានបញ្ចូលលេខសម្ងាត់ របស់ កាត អេ ធី អឹម ខុសចំនួន៣ដងជាប់ៗគ្នានៅម៉ាស៊ីនដក/ដាក់ប្រាក់ស្វ័យប្រវត្តិរបស់ អេ អឹម ខេ នោះ ម៉ាស៊ីននឹងលេបកាត អេ ធី អឹម នោះ ឬ បង្កការដកប្រាក់ចេញ ជាបណ្តោះអាសន្ន រហូតដល់ពេល **អតិថិជន** ជាម្ចាស់គណនី ធ្វើការស្នើសុំកាត និងភ្ជាប់ដំណើរការវិញ។
១១.៦.	**អតិថិជន** ត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកកាន់ **អេ អឹម ខេ** ឬ ទូរស័ព្ទមកកាន់នាយកដ្ឋានទំនាក់ទំនងសៅកម្មអតិថិជនប្រសិនបើ **អតិថិជន** ភ្លេចលេខសម្ងាត់។
១១.៧.	លេខកាត អេ ធី អឹម និងលេខសម្ងាត់ ជាព័ត៌មានសម្ងាត់ ដូចនេះ **អតិថិជន** មិនត្រូវប្រគល់កាត អេ ធី អឹម ឬ លេខសម្ងាត់ទៅ បុគ្គលណាម្នាក់ទេ។
១១.៨.	រាល់ការធ្វើឲ្យបាត់កាត អេ ធី អឹម ឬ ប្រគល់កាត អេ ធី អឹម ឲ្យអ្នកផ្សេងដោយម្ចាស់គណនីក្នុងគោលបំណងណាមួយ គឺជាការទទួលខុសត្រូវរបស់ម្ចាស់គណនី។
១១.៩.	រាល់បញ្ហាផ្សេងៗដែលកើតមានឡើងខុសប្រក្រតីទាក់ទងនឹងសមតុល្យក្នុងគណនី ឬ កាត អេ អឹម ខេ គ្រប់ប្រភេទ **អតិថិជន** ត្រូវទំនាក់ទំនងមកកាន់ **អេ អឹម ខេ** ជាបន្ទាន់។ ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំសើរើ ឬ ស្រាវជ្រាវមូលហេតុ ជាការធ្វេសប្រហែសរបស់**អតិថិជន**។ **អេ អឹម ខេ** រក្សាសិទ្ធិមិនស្រាវជ្រាវជូន **អតិថិជន** ទេ ប្រសិនបើ **អតិថិជន** ឬ អ្នកស្នើសុំ ពុំមានឯកសារ ឬ ព័ត៌មានជាអំណះអំណាង ឬ បញ្ហាដែលបានកើតឡើងយូរជាង៣០ថ្ងៃ។
១១.១០	**អតិថិជន** ត្រូវទាក់ទង មក អេ អឹម ខេ ភ្លាម តាមរយៈ ការិយាល័យ អេ អឹម ខេ ឬ ទូរស័ព្ទមកកាន់នាយកដ្ឋានទំនាក់ទំនងសៅកម្មអតិថិជនរបស់ **អេ អឹម ខេ** លេខ 023 22 02 02 ឬ 1800 200 200 ក្នុងករណីដែល កាត អេ ធី អឹម ខូចខាត ឬ បាត់បង់។ **អេ អឹម ខេ** មិនទទួលខុសត្រូវចំពោះប្រតិបត្តិការគណនី ឬ ផលវិបាកណាមួយ ដែលបានកើតមុនពេលជូនដំណឹងពីម្ចាស់គណនីទេ។
១១.១១	**អតិថិជន ត្រូវធ្វើតាមការណែនាំរបស់បុគ្គលិកការិយាល័យ អេ អឹម ខេ ឬតាមការណែនាំរបស់នាយកដ្ឋានទំនាក់ទំនងសៅកម្មអតិថិជនរបស់ អេ អឹម ខេ បន្ទាប់ពីធ្វើការទំនាក់ទំនងមកកាន់ អេ អឹម ខេ។**
១១.១២	ការស្នើសុំធ្វើកាតថ្មីជំនួស ឬ បន្ថែម ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ នៅតាមបណ្តាញប្រតិបត្តិការណាមួយ ដែលបានកំណត់ដោយ អេ អឹម ខេ។ អតិថិជនត្រូវបង់
១២. លក្ខខណ្ឌនៃការប្រើប្រាស់ ប័ណ្ណសន្សំ និងឥណ្ណាបនបត្រ	
១២.១.	**អតិថិជន** ត្រូវទាក់ទង មក អេ អឹម ខេ ភ្លាម តាមរយៈ ការិយាល័យ អេ អឹម ខេ ឬ ទូរស័ព្ទមកកាន់នាយកដ្ឋានទំនាក់ទំនងសៅកម្មអតិថិជនរបស់ **អេ អឹម ខេ** លេខ 023 22 02 02 ឬ 1800 200 200 ឬ បុគ្គលិករបស់ អេ អឹម ខេ ក្នុងករណីដែល ប័ណ្ណសន្សំ ឬ វិញ្ញាបនបត្រ ខូចខាត ឬ បាត់បង់។
១២.២.	**អតិថិជន ត្រូវធ្វើតាមការណែនាំរបស់បុគ្គលិកការិយាល័យ អេ អឹម ខេ ឬតាមការណែនាំរបស់នាយកដ្ឋានទំនាក់ទំនងសៅកម្មអតិថិជនរបស់ អេ អឹម ខេ បន្ទាប់ពីធ្វើការទំនាក់ទំនងមកកាន់ អេ អឹម ខេ។**
១២.៣.	ការស្នើសុំធ្វើ ប័ណ្ណសន្សំ ឬ វិញ្ញាបនបត្រ ជំនួស ឬ បន្ថែម ត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ នៅតាមបណ្តាញប្រតិបត្តិការណាមួយ ដែលបានកំណត់ដោយ អេ អឹម ខេ។ អតិថិជនត្រូវបង់កម្រៃសេវា យោងតាមគោលនយោបាយរបស់ អេ អឹម ខេ។
១៣. លក្ខខណ្ឌសេវាផ្តល់ព័ត៌មានលើគណនី	
១៣.១.	**អតិថិជន** អាចស្នើសុំ ភ្ជាប់សេវាផ្តល់ព័ត៌មានប្រតិបត្តិការលើគណនី ដោយទូរស័ព្ទមកកាន់នាយកដ្ឋានទំនាក់ទំនងសៅកម្មអតិថិជន **អេ អឹម ខេ** ឬ មកធ្វើការស្នើសុំផ្ទាល់នៅការិយាល័យ **អេ អឹម ខេ**។
១៣.២.	សារទូរស័ព្ទ ស្វ័យប្រវត្តិដែលផ្ញើចេញពី **អេ អឹម ខេ** មានឈ្មោះថា “AMK” ។ សារអេឡិចត្រូនិក ដែលផ្ញើចេញពី **អេ អឹម ខេ** ជាសារអេឡិចត្រូនិក ដែលមានកំណត់ក្នុងកិច្ចព្រមព្រៀង រវាង អតិថិជន និង អេ អឹម ខេ ឬ ដោយការជូនដំណឹងពី អេ អឹម ខេ។
១៣.៣.	**អេ អឹម ខេ** មិនទទួលខុសត្រូវចំពោះផលវិបាកទាំងឡាយណាដែលកើតចេញពី ភាពរអាក់រអួល ឬ កំហុសឆ្គងនៃប្រព័ន្ធទូរស័ព្ទ ឬ ប្រព័ន្ធទូរគមនាគមន៍ ឬ ប្រព័ន្ធបច្ចេកទេស របស់អ្នកផ្តល់ផ្តង់សេវាផ្ញើសារទេ។
១៣.៤.	**អតិថិជន** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកកាន់ **អេ អឹម ខេ** ឬ ទូរស័ព្ទមកកាន់នាយកដ្ឋានទំនាក់ទំនងសៅកម្មអតិថិជនរបស់ អេ អឹម ខេ ក្នុងករណីដែលលេខទូរស័ព្ទ ឬ អាសយដ្ឋានសារអេឡិចត្រូនិករបស់ខ្លួន បាត់បង់ ឬ ត្រូវបានផ្លាស់ប្តូរ។ អេ អឹម ខេ មិនទទួលខុសត្រូវចំពោះផលវិបាកទាំងឡាយណា ដែលបានកើតមានមុនពេលជូនដំណឹងពីម្ចាស់គណនីឡើយ។
១៣.៥.	**អតិថិជន** អាចស្នើសុំឈប់ប្រើប្រាស់ សេវាផ្តល់ព័ត៌មានលើគណនី ដោយទូរស័ព្ទមកកាន់នាយកដ្ឋានទំនាក់ទំនងសៅកម្មអតិថិជនរបស់ អេ អឹម ខេ ឬ មកកាន់ការិយាល័យ **អេ អឹម ខេ** ណាមួយ។
១៣.៦.	**អតិថិជន** អនុញ្ញាតឲ្យ **អេ អឹម ខេ** ផ្ញើ សេចក្តីជូនដំណឹងពីផលិតផលនិងសេវាកម្ម របស់ **អេ អឹម ខេ** តាមរយៈការផ្ញើសារទៅកាន់លេខទូរស័ព្ទដៃ (SMS) និង/ឬ សារអេឡិចត្រូនិក (Email)។
១៣.៧.	**អេ អឹម ខេ** រក្សាសិទ្ធិក្នុងការគិតកម្រៃសេវាផ្តល់ព័ត៌មានលើគណនីនេះ។ កម្រៃសេវា មានបង្ហាញនៅលើបណ្តាញផ្សព្វផ្សាយរបស់ អេ អឹម ខេ ដូចបានកំណត់ក្នុងចំណុច ២២។
១៤. លក្ខខណ្ឌនៃអត្រាការប្រាក់ កម្រៃសេវា និងអត្រាប្តូរប្រាក់	
១៤.១.	អត្រាការប្រាក់ គណនីសន្សំ ត្រូវបានផ្តល់ជូនទៅតាមតារាងអត្រាការប្រាក់ ដែលមានចែងក្នុងគោលនយោបាយ ដែលបានបង្ហាញនៅលើបណ្តាញផ្សព្វផ្សាយរបស់ អេ អឹម ខេ ដូចបានកំណត់ក្នុងចំណុច ២២។ **អេ អឹម ខេ** អាចផ្តល់អត្រាការប្រាក់ខុសៗគ្នាលើគណនីសន្សំមានកាលកំណត់ ដែលបានបើកនៅតាមបណ្តាញប្រតិបត្តិការរបស់ **អេ អឹម ខេ**។ អត្រាការប្រាក់នឹងត្រូវបានផ្តល់ឱ្យខុសៗគ្នា អាស្រ័យទៅលើចំណាយថ្លៃដើមរបស់ អេ អឹម ខេ។
១៤.២.	**អតិថិជន** ត្រូវបង់កម្រៃសេវា ប្រតិបត្តិការ ឬ សេវាផ្សេងៗ តាមការកំណត់របស់ **អេ អឹម ខេ** ដែលបានផ្សព្វផ្សាយតាមបណ្តាញផ្សព្វផ្សាយព័ត៌មានរបស់ **អេ អឹម ខេ**។
១៤.៣.	**អេ អឹម ខេ** រក្សាសិទ្ធិក្នុងការបន្ថែម ឬ លុបចោល ឬ កែប្រែនូវាល់អត្រាការប្រាក់ ឬ កម្រៃសេវា ឬ លក្ខខណ្ឌផ្សេងៗទៀតនៃប្រតិបត្តិការគណនី ដោយជូនដំណឹងដល់ **អតិថិជន** ដូចកំណត់ក្នុងចំណុច ២២។ ក្នុងករណីនេះ ប្រសិនបើអតិថិជនជ្រើសរើសយកលក្ខខណ្ឌបន្តដោយស្វ័យប្រវត្តិ សម្រាប់គណនីមានកាលកំណត់ នោះគណនីមានកាលកំណត់ដែលបានបន្តដោយស្វ័យប្រវត្តិនោះ នឹងត្រូវទទួលបានអត្រាការប្រាក់ថ្មី នៅកាលបរិច្ឆេទនៃការបន្តគណនីដោយស្វ័យប្រវត្តិ។ ដោយឡែក ប្រសិនបើអតិថិជនស្នើសុំបិទគណនីមុនកាលកំណត់ ឬស្នើសុំដកប្រាក់ចេញពីគណនីមានកាលកំណត់ មុនកាលបរិច្ឆេទដល់ពេលកំណត់ នោះអតិថិជនត្រូវធ្វើការជូនដំណឹងមក **អេ អឹម ខេ** យ៉ាងហោចណាស់ **៣០ ថ្ងៃប្រតិទិន** មុនកាលបរិច្ឆេទនៃការដកប្រាក់ ឬការបិទគណនីមានកាលកំណត់។
១៤.៤.	ប្រតិបត្តិការហិរញ្ញវត្ថុដែលត្រូវប្តូរប្រភេទរូបិយប័ណ្ណ ត្រូវអនុលោមទៅតាមអត្រាប្តូរប្រាក់ ដែលកំណត់ដោយ **អេ អឹម ខេ**។
១៥. លក្ខខណ្ឌនៃពន្ធអាករ និងការលើកលែងពន្ធអាករ	
១៥.១.	**អេ អឹម ខេ** មានតួនាទីនឹងកាតព្វកិច្ចកាត់ពន្ធកាត់ទុកពីអតិថិជនអនុលោមតាមច្បាប់សារពើពន្ធនឹងបទប្បញ្ញត្តិផ្សេងៗតម្រូវដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ពីការ

	ប្រាក់ដែល **អតិថិជន** ទទួលបាននៅរៀងរាល់ពេលបញ្ចូលការប្រាក់ចូលក្នុងគណនី។ **អ អឹម ខេ នឹង**មិនជូនដំណឹងដល់ម្ចាស់គណនីចំពោះការកាត់ពន្ធអាករដែលតម្រូវដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
១៥.២.	**អ អឹម ខេ** មានសិទ្ធិដកប្រាក់ចេញពីគណនីរបស់**អតិថិជន** ក្នុងគោលបំណងអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចព្រមព្រៀងដែលរាជរដ្ឋាភិបាលបាន ចូលរួមអនុវត្ត និងជាសមាជិក។
១៦. លក្ខខណ្ឌពាក់ព័ន្ធ និងអត្ថប្រយោជន៍ផ្សេងៗទៀត	
១៦.១.	**ចំពោះគណនីដែលភ្ជាប់នឹងការធានារ៉ាប់រង៖** ✓ **អ អឹម ខេ** រក្សាសិទ្ធិក្នុងការបន្ថែម ឬ លុបចោល ឬ កែប្រែអត្ថប្រយោជន៍ធានារ៉ាប់រងផ្សេងៗទាំងនោះគ្រប់ពេលវេលាដោយមិនចាំបាច់ជូនដំណឹងទៅកាន់**អតិថិជន**ជាមុនឡើយ ✓ **ក្រុមហ៊ុនធានារ៉ាប់រង** ជាស្ថាប័នតែមួយគត់ដែលមានសិទ្ធិនិងនិតិវិធីក្នុងការទូទាត់សំណងជូន **អតិថិជន**។ **អ អឹម ខេ** ពុំចូលរួមក្នុងប្រតិបត្តិការនិងនីតិវិធីការទូទាត់សំណងឡើយ
១៦.២.	**អត្ថប្រយោជន៍ផ្សេងៗទៀត ដែល អ អឹម ខេ ផ្តល់ជូន៖ អ អឹម ខេ** រក្សាសិទ្ធិក្នុងការបន្ថែម ឬ ការបន្ថយ ឬ ការលុបចោល ឬ ការកែប្រែកម្ចខណ្ឌនៃការផ្តល់អត្ថប្រយោជន៍ គ្រប់ពេលវេលា ដោយការជូនដំណឹងដូចកំណត់ក្នុងចំណុច ២២។
១៧. ឯកជនភាពព័ត៌មានរបស់អតថិជន	
១៧.១.	**អ អឹម ខេ** នឹងរក្សាការសម្ងាត់អំពីព័ត៌មានគណនី របស់ **អតិថិជន** ដោយមិនចែករំលែកទៅបុគ្គលណាម្នាក់ ដោយមិនមានការយល់ព្រមពី **អតិថិជន** ឡើយ។
១៧.២.	**អតិថិជន** យល់ព្រមឲ្យ **អ អឹម ខេ** ប្រើប្រាស់ និងចែករំលែកព័ត៌មានគណនី ដល់ក្រុមហ៊ុនមេ ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ សាខា ឬ ម្ចាស់ភាគហ៊ុន ឬ អភិបាល ឬ បុគ្គលិក ឬ សវនការ (ខាងក្នុង និងខាងក្រៅ) ឬ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ផ្សេងទៀត ឬ ភាគីទីបីក្នុងករណីចាំបាច់ណាមួយ ឬ អ្នកផ្គត់ផ្គង់សេវាកម្ម ឬ អ្នកប្រឹក្សាយោបល់របស់ **អ អឹម ខេ** យកទៅប្រើប្រាស់ដើម្បីរៀបចំទិន្នន័យ ធ្វើកិច្ចការរដ្ឋបាលផ្សេងៗ ស្រាវជ្រាវ ផ្សព្វផ្សាយទីផ្សារ និងផ្សេងៗ។
១៧.៣.	ចំពោះគណនីរបស់ **អតិថិជន** ណាមួយ ដែលមានភ្ជាប់អត្ថប្រយោជន៍ធានារ៉ាប់រង **អតិថិជន** បានយល់ព្រម អនុញ្ញាតឲ្យចែករំលែកព័ត៌មានរបស់ **អតិថិជន** និងព័ត៌មានគណនីរបស់ **អតិថិជន** ទៅកាន់ក្រុមហ៊ុនធានារ៉ាប់រង ដែលជាដៃគូរសហការរបស់ **អ អឹម ខេ** ក្នុងគោលបំណងផ្តល់អត្ថប្រយោជន៍ធានារ៉ាប់រងជូន**អតិថិជន**។
១៧.៤.	**អ អឹម ខេ** នឹងប្រគល់ព័ត៌មានសម្ងាត់របស់ អតិថិជន ដោយពុំជូនដំណឹងទៅ អតិថិជន ទេ ក្នុងករណីដែលមានការស្នើសុំពី ធនាគារជាតិនៃកម្ពុជា ឬ តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋាភិបាលបរទេសណាមួយ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងកិច្ចព្រមព្រៀងអន្តរជាតិដែលរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានចូលរួមអនុវត្ត និងជាសមាជិក។
១៨. ចំនួនទឹកប្រាក់ដែលត្រូវទូទាត់	
១៨.១.	**អតិថិជន** អនុញ្ញាតឲ្យ **អ អឹម ខេ** ធ្វើការបង្កកទុក ឬ ដកប្រាក់ ឬ ការផ្ទេរប្រាក់ចេញ ឬ ការកែតម្រូវ លើគណនីរបស់ **អតិថិជន** (គណនីសន្សំមានកាលកំណត់ ឬ គណនីមិនមានកាលកំណត់ ឬ គណនីមានកិច្ចសន្យា) ដោយពុំចាំបាច់ជូនដំណឹងដល់អតិថិជនជាមុន ដើម្បីទូទាត់នឹងប្រាក់ដូចខាងក្រោម៖ ✓ ប្រាក់កម្រៃសេវា ប្រាក់ពិន័យ ការចំណាយ ពន្ធអាករ សំណងខូចខាត ដែល **អតិថិជន** មិនទាន់បានទូទាត់ឲ្យ **អ អឹម ខេ** គ្រប់ចំនួន (បើមាន) ✓ ប្រាក់ដែល **អតិថិជន** បញ្ជាឲ្យធ្វើប្រតិបត្តិការ ហើយមិនទាន់បានទូទាត់ និងជាក់ទាក់រួចរាល់ (បើមាន) ✓ **ប្រាក់បំណុល ដែល អតិថិជន ជំពាក់ អ អឹម ខេ ទោះបីជាដល់កាលកំណត់ត្រូវសង ឬ មិនទាន់ដល់កាលកំណត់ត្រូវសង (បើមាន)** ✓ ប្រាក់ដែល **អតិថិជន** បាន ឬ កំពុងធានាកម្ចីណាមួយ ឬ កិច្ចសន្យាធានាណាមួយ ជាមួយនឹង **អ អឹម ខេ** (បើមាន) ប្រាក់ដែលបញ្ចូលក្នុងគណនីខុស (បើមាន)។
១៨.២.	**អតិថិជន** មិនត្រូវធ្វើប្រតិបត្តិការ ក្នុងករណីដែលសមតុល្យគណនីមិនមានគ្រប់គ្រាន់ ឬ ស្ថិតនៅក្រោមចំនួនអប្បបរមាដែល **អ អឹម ខេ** បានកំណត់។
១៩. ការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម	
១៩.១.	**អតិថិជន** យល់ព្រមឲ្យ **អ អឹម ខេ** ធ្វើការបង្កគណនី ឬ បង្កសមតុល្យគណនី ឬ ពន្យារពេល ឬ បដិសេធប្រតិបត្តិការគ្រប់ប្រភេទ ដោយមិនទទួលខុសត្រូវលើការខូចខាតអ្វីទាំងអស់ ប្រសិនបើមានការតម្រូវពីច្បាប់ ឬ បទបញ្ជា ពីធនាគារជាតិនៃកម្ពុជា ឬ តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
១៩.២.	<u>**គណនីដែលបើកដោយបុគ្គលិកផ្នែកលក់៖**</u> ✓ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ និងអនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គ្រប់គណនីដែលបើកដោយ បុគ្គលិកផ្នែកលក់ របស់ **អ អឹម ខេ** ត្រូវឆ្លងកាត់ការត្រួតពិនិត្យលើឯកសារស្នើសុំបើកគណនី និងឯកសារបញ្ជាក់អត្តសញ្ញាណដោយបុគ្គលិក **អ អឹម ខេ**។ ដូចនេះក្នុងកំឡុងពេលត្រួតពិនិត្យ **អតិថិជន** ពុំអាចធ្វើការដកប្រាក់ ឬ ផ្ទេរប្រាក់ ចេញពីគណនីបានទេ។ ✓ បន្ទាប់ពីការត្រួតពិនិត្យចប់ **អតិថិជន** អាចធ្វើការដកប្រាក់សន្សំចេញពីគណនីរបស់ខ្លួនបានជាធម្មតា។
១៩.៣.	**អតិថិជន** យល់ព្រមចូលរួមសហការ និងផ្តល់នូវឯកសារគាំទ្រនានា ដែលពាក់ព័ន្ធនឹងគណនី ឬ ប្រតិបត្តិការរបស់ខ្លួន ប្រសិនបើមានការតម្រូវពី **អ អឹម ខេ** ឬ ពីច្បាប់ ឬ បទបញ្ជារបស់ធនាគារជាតិនៃកម្ពុជា ឬ តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។
២០. មរណៈភាពរបស់ម្ចាស់គណនី ឬ ការបិទស្ថាប័នរបស់អតថិជនដែលមានគណនីស្ថាប័ន	
២០.១.	<u>**ចំពោះគណនីឯកត្តបុគ្គល**</u> ក្រោយពី **អតិថិជន** បានទទួលមរណៈភាព ញាតិលោហិត ឬ សហព័ទ្ធ របស់ **អតិថិជន** ត្រូវបង្ហាញជូន **អ អឹម ខេ** នូវឯកសារច្បាប់ដើមដូចរៀបរាប់ខាងក្រោម៖ ✓ លិខិតមរណៈភាព ✓ ឯកសារបញ្ជាក់កម្មសិទ្ធិលើគណនី ✓ ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់គណនី ✓ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅរបស់ម្ចាស់គណនី ✓ ឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកទទួលទ្រព្យសម្បត្តិ ✓ ឯកសារបញ្ជាក់អ្នកបន្តវេន (ទាយាទ) ស្របច្បាប់ (**«ឯកសារបញ្ជាក់មរតក»**) មានជាអាទិ៍៖ ក. សេចក្តីសម្រេចរបស់តុលាការ ពាក់ព័ន្ធនឹងមរតករបស់ម្ចាស់គណនី ខ. លិខិតមរតកសាសន៍ដែលមានសុពលភាពតាមផ្លូវច្បាប់ របស់ម្ចាស់គណនី

	គ. ឯកសារផ្លូវច្បាប់ផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល។ ✓ ក្នុងករណីអ្នកបន្តវេនស្របច្បាប់ មិនអាចបង្ហាញជូន **អេ អឹម ខេ** នូវឯកសារបញ្ជាក់មរតកខាងលើទេនោះ ដោយឆន្ទានុសិទ្ធិផ្តាច់មុខរបស់ខ្លួន **អេ អឹម ខេ** អាចពិចារណាក្នុងការទទួលយក កិច្ចព្រមព្រៀងក្នុងគ្រួសារម្ចាស់គណនីដែលយល់ព្រមប្រគល់ទ្រព្យសម្បត្តិបុគ្គលណាម្នាក់ដែលមានបោះត្រាបញ្ជាក់ពីឃុំ/សង្កាត់ ក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖ ក. បុគ្គលជាអ្នកបន្តវេនស្របច្បាប់ ប្រកាស និងអះអាង ជាលាយលក្ខណ៍អក្សរថា ខ្លួននឹងទទួលខុសត្រូវចំពោះមុខច្បាប់ ទៅលើគណនីរបស់ម្ចាស់គណនីដែលទទួលមរណៈភាព និងសិទ្ធិប្រយោជន៍ដែលមានភ្ជាប់ជាមួយគណនីនោះ ចំពោះបុគ្គលផ្សេងទៀត ដែលអះអាងថាខ្លួនជាអ្នកបន្តវេនស្របច្បាប់។ ការកាន់កាប់គណនីរបស់ម្ចាស់គណនីដែលទទួលមរណៈភាព គឺជាការកាន់កាប់ជំនួសម្ចាស់គណនីតែប៉ុណ្ណោះ។ និង ខ. ចំនួនទឹកប្រាក់នៅក្នុងគណនីរបស់ម្ចាស់គណនីដែលទទួលមរណៈភាព ដែលនឹងត្រូវផ្ទេរជូនអ្នកបន្តវេនស្របច្បាប់ មានចំនួនស្ថិតក្នុងកម្រិតដែលសមរម្យ អនុលោមតាមគោលនយោបាយផ្ទៃក្នុងរបស់ **អេ អឹម ខេ** ដែលអាចនឹងត្រូវបានកែប្រែជារឿយៗ។ **អេ អឹម ខេ** រក្សាសិទ្ធិក្នុងការ ត្រួតពិនិត្យ និងវិនិច្ឆ័យលើឯកសារ ដើម្បីសម្រេចក្នុងការប្រគល់ប្រាក់ ជូនបងប្អូន ឬ ញាតិ ឬ សហព័ទ្ធ របស់អតិថិជន។ សេចក្តីសម្រេចរបស់តុលាការ ឬ លិខិតមរតកសាសន៍ មានអានុភាពលើសកិច្ចព្រមព្រៀងក្នុងគ្រួសាររបស់ម្ចាស់គណនី។ **អេ អឹម ខេ** នឹងមិនទទួលខុសត្រូវចំពោះផលវិបាក នៃការខកខានមិនបានដាក់ជូននូវច្បាប់ចម្លងនៃលិខិតមរតកសាសន៍ឡើយ។
២០.២.	**ចំពោះគណនីរួម** បន្ថែមលើឯកសារដូចមានចែងក្នុងប្រការ ២១.១ នៅពេលម្ចាស់គណនីណាម្នាក់ទទួលមរណៈភាព ម្ចាស់គណនីទាំងអស់ផ្សេងទៀត ត្រូវស្នើសុំបិទ ឬ ត្រូវកែប្រែ ព័ត៌មានគណនីនោះដើម្បីដាក់ឈ្មោះអ្នកបន្តវេនស្របច្បាប់ អនុលោមតាមឯកសារបញ្ជាក់មរតកសាសន៍ ។
២០.៣.	**<u>ចំពោះគណនីស្ថាប័ន</u>** ✓ នៅពេលរំលាយស្ថាប័ន ក្នុងករណីណាក៏ដោយ ស្ថាប័នត្រូវមកបិទគណនីឲ្យបានមុនពេលស្ថាប័នត្រូវរំលាយជាស្ថាពរ។ ✓ ក្នុងករណីដែលស្ថាប័នបានរំលាយរួចរាល់ មុនពេលស្នើសុំបិទគណនី អ្នកមកបិទគណនីត្រូវតែបង្ហាញ៖ ក. លិខិតរំលាយស្ថាប័នដែលចេញពីអាជ្ញាធរមានសមត្ថកិច្ច ឬ សេចក្តីសម្រេចរបស់តុលាការ ដែលមានចាត់តាំងបុគ្គលណាម្នាក់មានសិទ្ធិបិទគណនី ឬ ខ. សេចក្តីសម្រេចជាឯកឆន្ទរបស់ ភាគទុនិក ឬ ក្រុមប្រឹក្សាភិបាល ក្នុងការបិទគណនី ស្របតាមលក្ខន្តិក:របស់ស្ថាប័ននោះដែលបានចេញនាពេលដែលស្ថាប័ននោះមានមិនទាន់បានរំលាយ ឬ គ. លិខិតស្នើសុំបិទគណនីជាឯកឆន្ទដែលចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃ ឬ ត្រា ពីអ្នកតំណាងស្របច្បាប់របស់ស្ថាប័ន។
២០.៤.	ករណីណាមួយដែលមានរៀបរាប់ខាងលើអាចនឹងមានការប្រែប្រួលទៅតាមតម្រូវការជាក់ស្តែង ឬផ្លូវច្បាប់។
២១. គណនីដែលមើលការពេលអនាគត	
អតិថិជនយល់ព្រមថាលក្ខខណ្ឌទូទៅនៃគណនីប្រាក់សន្សំនេះ រួមជាមួយលក្ខខណ្ឌបន្ថែមណាមួយ ឬលក្ខខណ្ឌដែលបានកែប្រែ ឬលុបចោល ឬផ្លាស់ប្តូរណាមួយ ត្រូវប្រើប្រាស់ចំពោះគណនីដែលអតិថិជនអាចនឹងមានជាមួយ **អេ អឹម ខេ** នៅថ្ងៃអនាគតផងដែរ។	
២២. ប្រព័ន្ធផ្សព្វផ្សាយ និងការជូនដំណឹង	
រាល់លក្ខខណ្ឌ ដែលមានចែងនៅក្នុងលក្ខខណ្ឌទូទៅនៃគណនីប្រាក់សន្សំនេះ និងរាល់លក្ខខណ្ឌជាក់លាក់ដែលមានចែងលើខិត្តប័ណ្ណផ្សព្វផ្សាយ អាចនឹងមានការកែប្រែ។ **អេ អឹម ខេ** នឹងធ្វើការជូនដំណឹងទៅកាន់ **អតិថិជន** ជាម្ចាស់គណនីឲ្យបានឆាប់រហ័សបំផុត តាមដែលអាចធ្វើទៅបាន ដោយការទំនាក់ទំនងទៅកាន់អាសយដ្ឋាន ឬ លេខទូរស័ព្ទ ឬ អាសយដ្ឋានសារអេឡិចត្រូនិកដែល**អតិថិជន**ផ្តល់ជូន ឬ ដោយការផ្សព្វផ្សាយនៅតាមការិយាល័យ **អេ អឹម ខេ** ឬ នៅទីតាំងភ្នាក់ងារ **អេ អឹម ខេ** ឬ នៅលើគេហទំព័រ របស់ **អេ អឹម ខេ** www.amkbank.com.kh ឬតាមប្រព័ន្ធផ្សព្វផ្សាយនាៗរបស់ **អេ អឹម ខេ**។ ប្រសិនបើអតិថិជនមិនយល់ព្រមតាមលក្ខខណ្ឌដែលបានធ្វើការផ្លាស់ប្តូរ អតិថិជនអាចធ្វើការបិទគណនីដែលមាននៅ **អេ អឹម ខេ**។ ប្រសិនបើអតិថិជននៅរក្សាការប្រើប្រាស់គណនីនៅ **អេ អឹម ខេ** នោះមានន័យថាអតិថិជនយល់ព្រមតាមការកែប្រែលើលក្ខខណ្ឌទូទៅនៃគណនីសន្សំនេះ។	
២៣. ច្បាប់អនុវត្ត	
២៣.១.	រាល់លក្ខខណ្ឌដែលមានចែងក្នុងលក្ខខណ្ឌទូទៅនៃគណនីប្រាក់សន្សំនេះ ត្រូវធ្វើឡើងស្ថិតនៅក្រោមការគ្រប់គ្រងដោយច្បាប់របស់ ព្រះរាជាណាចក្រកម្ពុជា។
២៣.២.	ក្នុងករណីដែលមានភាពមិនត្រូវគ្នារវាងភាសាអង់គ្លេស និងភាសាខ្មែរនៃលក្ខខណ្ឌទូទៅនៃគណនីប្រាក់សន្សំនេះ ភាសាខ្មែរ ត្រូវយកជាគោល។